00495855



**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ការិយាល័យសហចៅក្រមស៊ើបអង្កេត
## OFFICE OF THE CO-INVESTIGATING JUDGES
## BUREAU DES CO-JUGES D'INSTRUCTION
## អនុស្សរណៈអន្តរការិយាល័យ

ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០

ជូនចំពោះ: **លោក-លោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ស៊ីន សុវន ហុង គីមសួន
ជេត វណ្ណលី គីម ម៉េងឃី ម៉ុច សុវណ្ណារី
**Martine JACQUIN, Philippe CANONNE, Annie DELAHAIE, Elizabeth RABESANDRATANA, Fabienne TRUSSES-NAPROUS, Laure DESFORGES, Christine MARTINEAU, Isballe DURAND, Françoise GAUTRY, Silke STUDZINSKY**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 04 / 2010
ម៉ោង (Time/Heure): 10 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

សាធារ
PUBL

ចម្លងជូន: Dr. Helen JARVIS, ប្រធាន
Paul Oertly, អនុប្រធាន
**អង្គភាពគាំពារជនរងគ្រោះ**

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 12 / 04 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ពី: **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម** Marcel Lemonde
សហចៅក្រមស៊ើបអង្កេត

កម្មវត្ថុ: **ឆ្លើយតប: ពេលវេលាកំណត់សម្រាប់ដាក់ព័ត៌មានបន្ថែម**

យើង បញ្ជាក់ថាបានទទួលរួចហើយនូវពាក្យសុំរបស់លោក-លោកស្រីមេធាវីចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១០[1] ដែលស្នើសុំ "*ពន្យាពេលផុតកំណត់ ១ (មួយ) ខែបន្ថែមទៀត គឺរហូតដល់ថ្ងៃទី៣១*

[1] D337/2

*ខែឧសភា ឆ្នាំ២០១០"* ដើម្បីដាក់ព័ត៌មាន បន្ថែមទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដំបូងដែលបានដាក់ជាមួយអង្គភាពគាំពារជនរងគ្រោះ។

ដើម្បីគាំទ្រសំណើរបស់លោក-លោកស្រីមេធាវី លោក-លោកស្រីមេធាវីបានលើកយកសេចក្តីសម្រេចរបស់យើង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០[2] ដែលទាក់ទងនឹងការបន្ថែមរយៈពេលមួយខែ ដល់អង្គភាពគាំពារជនរងគ្រោះដើម្បីដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកការិយាល័យសហចៅក្រមស៊ើបអង្កេត។

យើងយល់ថាជាការសំខាន់ដើម្បីរំលឹកលោក-លោកស្រីមេធាវី ថា ជនរងគ្រោះដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ ត្រូវបានអនុញ្ញាតឲ្យបំពេញព័ត៌មានបន្ថែមលើពាក្យសុំរបស់ពួកគេ[3]ប្រសិនបើចាំបាច់ ស្របតាមស្មារតីនៃសេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតស្តីពីដែននៃកិច្ចស៊ើបសួរចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០។ លទ្ធភាពនេះ មិនមានពាក់ព័ន្ធគ្នាជាមួយនឹងការដាក់សំណុំឯកសារព័តមានជនរងគ្រោះមកការិយាល័យសហចៅក្រមស៊ើបអង្កេតដោយអង្គភាពគាំពារជនរងគ្រោះនោះទេ។ ជាផលវិបាក ការពន្យាពេលវេលាកំណត់ដល់អង្គភាពគាំពារជនរងគ្រោះដើម្បីដាក់សំណុំឯកសារព័តមានជនរងគ្រោះមកការិយាល័យសហចៅក្រមស៊ើបអង្កេត មិនទាក់ទងអ្វីនឹងលទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការដាក់ព័ត៌មានបន្ថែមនោះទេ ហើយក៏គ្មានហេតុផលណាដែលនាំឲ្យគេភ្ជាប់ពេលវេលាកំណត់ទាំងពីរនេះជាមួយគ្នាដែរ។

អាស្រ័យហេតុនេះ ពេលវេលាកំណត់ដែលមានកំណត់នៅក្នុងអនុស្សារណៈអន្តរការិយាល័យ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ នៅតែរក្សាដដែល[4]។

យើង ចង់ចាំជានិច្ចនូវសារសំខាន់ដែលថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវអាចមើល បាន ឆាប់តាមដែលអាចធ្វើបាន នូវទម្រង់ព័តមានជនរងគ្រោះ និង នៅពេលណាដែលមានអត្ថិភាព នូវឯកសារគាំទ្រដ៏ទៃទៀត ដូចជា របាយការណ៍ស្តីពីជនរងគ្រោះម្នាក់ៗ (ដែលមានការសង្ខេបជាភាសាអង់គ្លេសនូវបទចោទនិងអង្គហេតុ ។ល។) ពាក់ព័ន្ធនឹងកូនក្តីរបស់ខ្លួន ក្រោមលក្ខខណ្ឌដែលមេធាវីទាំងនោះ មានលិខិតផ្ទេរសិទ្ធិពីកូនក្តីខ្លួនដែលមានតម្កល់ទុកជាមួយអង្គភាពគាំពារជនរងគ្រោះ។ ដោយសាមូលហេតុនេះហើយដែលកាលពីពេលថ្មីៗនេះ យើង បានអនុញ្ញាតឲ្យអង្គភាពគាំពារជនរង

[2] D337/1

[3] តាមរយៈប្រព័ន្ធផ្សព្វផ្សាយចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០

[4] D337

គ្រោះផ្តល់ឯកសារទាំងនោះទៅឲ្យមេធាវីពាក់ព័ន្ធ ទោះបីជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ ត្រូវបានដាក់ឬមិនទាន់ត្រូវបានដាក់ចូលក្នុងសំណុំរឿងក៏ដោយ។